[S 00000065-00000073]

# សារព័ត៌មានក្រុងប៉េកាំង “RENMIN RIBAO” ទទួលស្វាគមន៍គណៈប្រតិភូនៃរណសិរ្ស រួបរួមជាតិកម្ពុជា (FUNK) និងរាជរដ្ឋាភិបាល រួបរួមជាតិកម្ពុជា (GRUNK)

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Jun-2011, 08:56
CMS/CFO: Phok Chanthan

## ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៧៤

នៅក្នុងវិចារណកថាមួយរបស់ខ្លួន ចុះថ្ងៃទី ១ ខែ មេសា មានចំណងជើងថា “ស្វាគមន៍យ៉ាងកក់ក្តៅចំពោះមិត្តរួមអាវុធដែលបានធ្វើដំណើរមកពីវីរទឹកដីកម្ពុជា” សម្រាប់ស្វាគមន៍ដំណើរទស្សនកិច្ចជាផ្លូវការ និងជាលក្ខណៈមិត្តភាពនៅសាធារណរដ្ឋប្រជាមានិតចិន កាលពីថ្ងៃទី ១ ខែ មេសា របស់គណៈប្រតិភូនៃ FUNK និងGRUNK សារព័ត៌មាន RENMIN RIBAO បានសរសេរថា៖

“នៅក្នុងស្ថានភាពដ៏វិសេសវិសាល ដែលប្រជាជនកម្ពុជាដណ្តើមបានជ័យជំនះដ៏ត្រចះត្រចង់ក្នុងសង្គ្រាមប្រឆាំងនឹងការឈ្លានពានរបស់សហរដ្ឋអាមេរិក និងដើម្បីធ្វើការស្រោចស្រង់ជាតិ គណៈប្រតិភូនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានលោក ខៀវ សំផន ជាប្រធាន និងជាសមាជិកការិយាល័យនយោបាយនៃគណៈមជ្ឈិមរបស់ FUNK ជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិនៃ GRUNK និងជាអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិ ព្រមទាំងលោក អៀង សារី ជាអនុប្រធាន និងជាទីប្រឹក្សាពិសេសរបស់ក្រុមប្រឹក្សារងនៃ GRUNK ក្រោមការអញ្ជើញរបស់រដ្ឋាភិបាលនៃប្រទេសចិន បានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ និងជាលក្ខណៈមិត្តភាពថ្ងៃនេះ ក្នុងទីក្រុងប៉េកាំង។ គណៈប្រតិភូក្នុងដំណើរទស្សនកិច្ចនេះ គឺជាគណៈប្រតិភូសំខាន់ដែលបានមកបំពេញទស្សនកិច្ចក្នុងប្រទេសចិន ដោយធ្វើដំណើរមកពីខាងក្នុងប្រទេសកម្ពុជា។ គណៈប្រតិភូនេះនឹងពាំនាំដំណឹងមកប្រាប់ប្រជាជនចិន ដែលស្ថិតនៅសមរភូមិក្រោយអំពីជ័យជំនះរបស់រណសិរ្ស ព្រមទាំងមនោសញ្ចេតនាមិត្តភាពដ៏ជ្រាលជ្រៅ នៃមិត្តរួមអាវុធដែលកំពុងធ្វើការតស៊ូប្រយុទ្ធនៅសមរភូមិមុខ។ ក្នុងមនោសញ្ចេតនារីករាយ និងស្និទស្នាល ប្រជាជនចិនបានសម្តែងនូវការជូនពរ និងទទួលស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះយុទ្ធមិត្ត ដែលអញ្ជើញមកពីវីរទឹកដីកម្ពុជា និងសូមសម្តែងនូវការគោរពចំពោះប្រជាជនកម្ពុជាជាបងប្អូនផងដែរ។

“ប្រជាជនកម្ពុជា គឺជាប្រជាជនដែលក្លាហាន និងរឹងមាំ។ ដើម្បីការពារនូវឯករាជ្យជាតិ អធិបតេយ្យភាពរបស់រដ្ឋ និងបូរណភាពដែនដី ប្រជាជនកម្ពុជាបានធ្វើការតស៊ូប្រយុទ្ធដ៏យូរអង្វែង ប្រឆាំងទៅនឹងការឈ្លានពានរបស់បរទេស។ ក្រោយពីរដ្ឋប្រហារប្រតិកិរិយា ដែលបានធ្វើឡើងកាលពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧០ ដោយ លន់ នល់ ដោយមានការជួយជ្រោមជ្រែងពីសំណាក់សហរដ្ឋអាមេរិក ប្រជាជនកម្ពុជា ក្រោមការដឹកនាំរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេចព្រះនរោត្តមសីហនុជាប្រធាន បានធ្វើការតស៊ូប្រយុទ្ធដ៏ខ្លាំងក្លា និងគួរឲ្យកត់សម្គាល់ ប្រឆាំងនឹងចក្រពត្តិនិយមអាមេរិក និងបនក្បត់ លន់ នល់ ដើម្បីសម្រេចឲ្យបានស្របតាមសេចក្តីថ្លែងការណ៍ ៥ ចំណុច និងកម្មវិធីនយោបាយរបស់រណសិរ្ស ដែលស្តែងឡើងតាមរយៈការពុះពារទៅមុខប្រកបដោយវីរភាព និងប្រកបដោយជោគជ័យដ៏អស្ចារ្យ ដើម្បីបុព្វហេតុឯករាជ្យជាតិរបស់កម្ពុជា។ បច្ចុប្បន្ននេះ ការតស៊ូប្រយុទ្ធតទល់នឹងការឈ្លានពានរបស់អាមេរិក ដើម្បីស្រោចស្រង់ជាតិ បានទទួលជោគជ័យដ៏ធំធេង។ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិ បានទទួលជ័យជំនះដ៏ខ្លាំងក្លាក្នុងសមរភូមិប្រយុទ្ធនានា។ វិសាលភាពនៃទឹកដីមួយផ្នែកធំត្រូវបានរំដោះ ហើយអំណាចប្រជាធិបតេយ្យមានលក្ខណៈកាន់តែរឹងមាំជាដរាប។ តំបន់រំដោះមានសភាពរីកចម្រើននៅគ្រប់ទីកន្លែង។ ម្យ៉ាងទៀត ព័ត៌មានអំពីជ័យជំនះបាននាំមកដល់យើង ពីសមរភូមិប្រយុទ្ធក្នុងប្រទេសកម្ពុជា ជាបន្តបន្ទាប់។ ក្រោមកណ្តាប់ដៃដ៏ធ្ងន់ធ្ងររបស់កងទ័ព និងប្រជាជនអ្នកស្នេហាជាតិ បនក្បត់ លន់ នល់ ដែលធ្លាក់ទៅក្នុងការលំបាកកាន់តែធំឡើងៗ នឹងឈានទៅរកភាពរលាយបាត់បង់យ៉ាងឆាប់រហ័ស”។

អត្ថបទនោះបានគូសបញ្ជាក់ថា៖

“ការតស៊ូប្រយុទ្ធដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជាបានទទួលនូវការគាំទ្រ និងការកោតស្ញប់ស្ញែងពីសំណាក់ប្រជាជននៅក្នុងពិភពលោក។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានសម្តេចនរោត្តម សីហនុ ជាប្រធាន បានផ្សារភ្ជាប់ទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសមួយចំនួនធំ ហើយទទួលបាននូវកិត្យានុភាពល្បីរន្ទឺពាសពេញពិភពលោក។ ប្រជាជនចិនសូមធ្វើការអបអរសាទរយ៉ាងកក់ក្តៅដល់មហាជ័យជំនះដែលប្រជាជនកម្ពុជាដណ្តើមបាននៅរាល់សមរភូមិមុខទាំងឡាយ ហើយសូមជូនពរដោយស្មោះអស់ពីដួងចិត្ត ដល់ប្រជាជនកម្ពុជាឲ្យដណ្តើមបានជ័យជំនះកាន់តែធំឡើងៗ នៅក្នុងការតស៊ូប្រយុទ្ធនាពេលអនាគត។

“ក្នុងពេលបច្ចុប្បន្ននេះ ស្ថានភាពអន្តរជាតិបានបន្តវិវត្តក្នុងទិសដៅមួយល្អប្រសើរសម្រាប់ប្រជាជននៃប្រទេសនានា។ ប្រទេសនានាចង់បានឯករាជ្យ ប្រជាជាតិនានាចង់បានការរំដោះជាតិ និងប្រជាជននានាត្រូវការបដិវត្តន៍។ ចរន្តជាប្រវត្តិសាស្ត្រនេះបានបោះជំហានទៅមុខយ៉ាងខ្លាំងក្លា ហើយពុំមានកម្លាំងណាមួយអាចបំបែកបាន។ ការតស៊ូប្រយុទ្ធរបស់ប្រជាជនកម្ពុជាប្រឆាំងនឹងការឈ្លានពានរបស់អាមេរិក ដើម្បីស្រោចស្រង់ជាតិ ជាមួយនឹងជ័យជំនះរបស់ពួកគេ បានបង្ហាញយ៉ាងជាក់ច្បាស់ដោយមិនអាចប្រកែកបានថា មានតែប្រជាជននៃបណ្តាប្រទេសនានាដែលតស៊ូប្រយុទ្ធដើម្បីយុត្តិធម៌ប៉ុណ្ណោះ ដែលមានភាពខ្លាំងពូកែពិតប្រាកដ ហើយពុំមែនពួកចក្រពត្តិនិយមឡើយ ដែលពួកនេះមានភាពខ្លាំងពូកែតែសំបកក្រៅប៉ុណ្ណោះ។ ប្រជាជាតិ និងប្រជាជនទាំងឡាយដែលជាជនរងគ្រោះ នៃការរំលោភឈ្លានពាន អាចបោះជំហានចេញពីស្ថានភាពទន់ខ្សោយ ឈានទៅរកភាពខ្លាំងពូកែ ហើយទទួលបានជ័យជំនះនៅក្នុងការតស៊ូប្រយុទ្ធប្រឆាំងនឹងការឈ្លានពានបាន ដរាបណាពួកគេរួបរួមគ្នាជាធ្លុងមួយ ហ៊ានធ្វើការតស៊ូប្រយុទ្ធ មានភាពអំណត់ព្យាយាមក្នុងការធ្វើសង្គ្រាមប្រជាជន ហើយនិងធ្វើការថ្លឹងថ្លែងជានិច្ច នូវបទពិសោធន៍នានាដែលទទួលបានពីការតស៊ូប្រយុទ្ធរបស់ពួកគេ។

“ប្រជាជនចិន និងប្រជាជនកម្ពុជាគឺជាមិត្តរួមអាវុធ និងជាបងប្អូននឹងគ្នា។ ពួកយើងស្ថិតក្នុងចង្កោមគ្រួសារតែមួយ។ នៅក្នុងការតស៊ូប្រយុទ្ធរួមគ្នាប្រឆាំងនឹងចក្រពត្តិនិយម យើងបានធ្វើការជំរុញនិងគាំទ្រ ព្រមទាំងផ្សារភ្ជាប់នូវចំណងមិត្តភាពដ៏ជ្រាលជ្រៅលើសមរភូមិប្រយុទ្ធ។ ការវាយប្រយុទ្ធរបស់ប្រជាជនកម្ពុជា ព្រមទាំងជ័យជំនះរបស់ពួកគេ បានបង្កើតឲ្យមានជាការលើកទឹកចិត្ត និងការគាំទ្រយ៉ាងខ្លាំងក្លាដល់ប្រជាជនចិន។ ប្រជាជនចិនតែងតែចាត់ទុកថាការវាយប្រយុទ្ធរបស់ប្រជាជនកម្ពុជាជាការវាយប្រយុទ្ធរបស់ប្រជាជនចិន និងចាត់ទុកថាការគាំទ្រដល់បុព្វហេតុដ៏ត្រឹមត្រូវរបស់ពួកគេ គឺជាកាតព្វកិច្ចជាអន្តរជាតិដែលត្រូវបំពេញ។ នៅពេលអនាគត ក៏ដូចជាក្នុងអតីតកាល យើងខ្ញុំសូមចូលរួមជាមួយប្រជាជនកម្ពុជាជាបងប្អូន និងសូមធ្វើការគាំទ្រដាច់ខាតដល់បុព្វហេតុដ៏ ត្រឹមត្រូវរបស់ពួកគេ។

“យើងខ្ញុំមានជំនឿយ៉ាងមុតមាំថា ដំណើរទស្សនកិច្ចនៅប្រទេសចិនរបស់គណៈប្រតិភូនៃ FUNK និង GRUNK នឹងពង្រឹងបាន និងធ្វើឲ្យរីកចម្រើនដល់ចំណងមិត្តភាពបដិវត្តន៍ ព្រមទាំងសាមគ្គីភាពលើសមរភូមិប្រយុទ្ធរវាងប្រជាជនចិន និងប្រជាជនកម្ពុជា ហើយនឹងបង្កើតបានជាជំពូកថ្មីមួយនៅក្នុងកម្រងវណ្ណកម្មមិត្តភាពរវាងប្រទេសទាំងពីរ។ យើងខ្ញុំសូមប្រសិទ្ធិពរជ័យសូមឲ្យដំណើរទស្សនកិច្ចនេះបានប្រព្រឹត្តទៅប្រកបដោយជោគជ័យ។

# ក្រុងប៉េកាំងរៀបចំទទួលស្វាគមន៍ដ៏ឱឡារិក និងកក់ក្ដៅ ចំពោះគណៈប្រតិភូនៃ FUNK និង GRUNK

## ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៧៤

គណៈប្រតិភូនៃ FUNK និង GRUNK ដែលមានលោក ខៀវ សំផន ជាប្រធាន ហើយដែលលោកជាសមាជិកការិយាល័យនយោបាយនៃគណៈមជ្ឈិមរបស់ FUNK ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិរបស់ GRUNK និងជាអគ្គមេបញ្ជាការនៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ព្រមទាំងលោក អៀង សារី ដែលជាទីប្រឹក្សាពិសេសនៃអនុប្រធានក្រុមប្រឹក្សារបស់ GRUNK បានអញ្ជើញមកដល់ទីក្រុងប៉េកាំង កាលពីថ្ងៃទី ១ ខែ មេសា តាមជើងហោះហើរពិសេសដែលចេញដំណើរមកពីទីក្រុងហាណូយ ដើម្បីបំពេញទស្សនកិច្ចជាមិត្តភាព និងជាផ្លូវការនៅប្រទេសចិន ក្រោមការអញ្ជើញរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។

មានវត្តមាននៅព្រលានយន្តហោះ ដើម្បីទទួលស្វាគមន៍គណៈប្រតិភូ រួមមានមេដឹកនាំនៃបក្សកុម្មុយនីស្តចិន និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន លោក ជូ អេនឡាយ លោក យី គានយីង លោក ចេន ស៊ីលាន លោក វូ តេ និងលោក ស៊ូ ចេនហួរ។

ពិធីបដិសណ្ឋារកិច្ចត្រូវបានផ្តល់ជាកិត្តិយសក្រោមព្រះរាជវត្តមានរបស់ សម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋ និងជាប្រធាននៃ FUNK សម្តេច ប៉ែន នុត ប្រធានការិយាល័យនយោបាយនៃគណៈមជ្ឈិមរបស់ FUNK និងជានាយករដ្ឋមន្ត្រីនៃ GRUNK ។

មានវត្តមានផងដែរនៅព្រលានយន្តហោះ ដើម្បីទទួលស្វាគមន៍គណៈប្រតិភូ រួមមាន រដ្ឋមន្ត្រី និងឧបនាយករដ្ឋមន្ត្រីនានានៃ GRUNK ដែលមានលោក ជួន មុំ លោក គាត ឈន់ លោក វ៉ាន់ ពិនី សមាជិកនៃក្រុមញាតិវង្ស ជំនាញការ និងនិស្សិតកម្ពុជាដែលកំពុងបន្តការសិក្សានៅទីក្រុងប៉េកាំង ក៏ដូចជាមន្ត្រីការទូតនៃបណ្តាប្រទេសនានាដែលកំពុងបំពេញបេសកកម្មការទូតក្នុងប្រទេសចិន។

លោក សារិន ឆាក លោកឧត្តមសេនី ឌួង សំអុល និងលោក ជួន ប្រសិទ្ធ រដ្ឋមន្ត្រីនៃ GRUNK និងលោក កៅ គានចុង អនុប្រធាននាយកដ្ឋានពិធីការនៃក្រសួងការបរទេសចិន ដែលបានអញ្ជើញទៅកាន់ទីក្រុងហាណូយដើម្បីទទួលស្វាគមន៍គណៈប្រតិភូ ក៏បានអញ្ជើញត្រលប់មកទីក្រុងប៉េកាំងវិញតាមជើងយន្តហោះតែមួយផងដែរ។

សមាជិកនៃគណៈប្រតិភូរួមមានលោកស្រី អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងអប់រំប្រជាជន និងយុវជននៃ GRUNK លោក ទីវ អុល អនុរដ្ឋមន្ត្រីក្រសួងព័ត៌មាន និងឃោសនាការ លោក តូច ខាំឌឿន ឯកអគ្គរដ្ឋទូតនៃប្រទេសកម្ពុជាប្រចាំនៅប្រទេសចិន។

នៅទីក្រុងប៉េកាំង វិថីដែលតភ្ជាប់វិមានធានអានម៉េង ទៅកាន់វិមានរដ្ឋាភិបាល ត្រូវបានរំលេចទៅដោយទង់ចម្រុះពណ៌ និងទង់ជាតិនៃប្រទេសចិន និងកម្ពុជា ដែលបក់រវិចៗតាមខ្យល់។ ទីលានធានអានម៉េង ដែលតុបតែងដោយគោមយក្សពណ៌ក្រហមចំនួន ៨ ហើយវិមានដែលស្ថិតនៅជ្រុងទាំងពីរនៃទីលានមានដោតទង់ក្រហមជាច្រើន ហើយនៅតាមដងមហាវិថីមានលើកបដាដែលមានសរសេរ ជាអក្សរខ្មែរ និងអក្សរចិនថា៖ "យើងគាំទ្រដាច់ខាតដល់ការតស៊ូប្រយុទ្ធរបស់ប្រជាជនកម្ពុជាប្រឆាំងនឹងការឈ្លានពានរបស់អាមេរិក និងដើម្បីធ្វើការស្រោចស្រង់ជាតិ!" "យើងគាំទ្រដាច់ខាតការតស៊ូប្រយុទ្ធដ៏ត្រឹមត្រូវរបស់ប្រជាជនទាំងបីនៃឥណ្ឌូចិន!" "ស្វាគមន៍វីរប្រជាជនកម្ពុជា" "ជយោមិត្តភាព និងសាមគ្គីភាពដ៏ធំធេងរវាងប្រជាជនចិន និងប្រជាជនកម្ពុជា!" "ជយោ សាមគ្គីភាពដ៏ធំធេងរបស់ប្រជាជននៅក្នុងពិភពលោក!"។

ទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសចិនបានបក់រវិចៗនៅព្រលានយន្តហោះនារដ្ឋធានីប៉េកាំង។

នៅវេលាម៉ោង ៣ រសៀល ប្រធានគណៈប្រតិភូ លោក ខៀវ សំផន និងអនុប្រធាន អៀង សារី និងមិត្តរួមអាវុធកម្ពុជាបានចុះពីលើយន្តហោះ ក្រោមសម្លេងទះដៃអបអរសាទរ សម្លេងទូងស្គរ និងគង យ៉ាងកងរំពងអឺងអាប់។ សម្ដេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ នាយករដ្ឋមន្ត្រី ប៉ែន នុត នាយករដ្ឋមន្ត្រី ជូ អេនឡាយ លោកអនុប្រធាន យី គានយីង បានអញ្ជើញទៅទល់មុខគណៈប្រតិភូ ដើម្បីចាប់ដៃ និងឧបគ្គាប្រកបដោយភាពកក់ក្ដៅ។

បន្ទាប់ពីមានការប្រគុំភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា និងប្រទេសចិន ភ្ញៀវកិត្តិយសកម្ពុជា ដែលរួមដំណើរដោយថ្នាក់ដឹកនាំបក្ស និងរដ្ឋាភិបាលនៃប្រទេសចិន បានដើរត្រួតពលកងកម្លាំងនៃកងទ័ពជើងគោក ជើងទឹក និងជើងអាកាសនៃកងទ័ពប្រជាជនរំដោះ នៃសាធារណរដ្ឋប្រជាមានិតចិន។

នៅពេលដែលភ្ញៀវកិត្តិយសកម្ពុជាបានធ្វើដំណើរមួយជុំចុះមកដីដើម្បីស្វាគមន៍ហ្វូងមនុស្សមានយុទ្ធជន និងយុទ្ធនារីរាប់រយនាក់ក្នុងកងពលនៃកងទ័ពប្រជាជនរដ្ឋធានី បានគំនាប់អាវុធដល់គណៈប្រតិភូ។ លោក ខៀវ សំផន និងលោក អៀង សារី បានចាប់ដៃពួក គេយ៉ាងជិតស្និទ្ធ និងបានថតរូប

អនុស្សាវរីយ៍ជាមួយពួកគេផងដែរ។ ក្នុងកាយវិការដ៏រំភើប យុទ្ធជន យុទ្ធនារីបានសម្តែងនូវការសប្បាយរីករាយដែលបានមានឱកាសមកទទួលស្វាគមន៍គណៈប្រតិភូរបស់ FUNK និង GRUNK ព្រមទាំងមិត្តរួមអាវុធលើសមរភូមិទាំងឡាយ ដែលអញ្ជើញមកក្នុងប្រទេសចិន។ កុមារា កុមារី ដែលកាន់បាច់ផ្កា និងស្បៃចម្រុះពណ៌នៅក្នុងដៃ បានរាំយ៉ាងរីករាយ និងស្រែកឥតឈប់ថា៖ “សូមស្វាគមន៍ សូមស្វាគមន៍ សូមស្វាគមន៍យ៉ាងកក់ក្តៅ”។ លោក ខៀវ សំផន និងលោក អៀង សារី ក៏មិនឈប់លើកដៃស្វាគមន៍តបទៅពួកគេវិញដែរ។

មានវត្តមាននៅឱកាសនោះផងដែរ លោក កេង ពាវ ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៃគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន លោក គី ប៉េងហ្វី រដ្ឋមន្ត្រីក្រសួងការបរទេស លោក លី គាង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្រៅប្រទេស លោក លាវ ស៊ាងពីង រដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ លោក ស៊ាវ គីនគួង អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ លោក លី តា នាយអគ្គសេនាធិការរងនៃកងទ័ពប្រជាជនរំដោះ នៃប្រទេសចិន លោក លីន គាវចេ និងលោក ហ៊ូ យូចេ សមាជិកគណៈអចិន្ត្រៃយ៍នៃសភាជាតិប្រជាជន លោក ហាន នានឡុង លោក ចេន គាន លោក ហាន សុងចេន លោក ហ្វ៊ាង ហៃហុង លោក ចាង សុងសួន លោក វៃ ប៉ូទីង លោក ម៉ាន នីង លោក កុង ចៅនាន លោក ជូ ហ្វៃផេង លោកទីង ស៊ាវសុង លោក ស៊ី លីហ្វូ និងលោក ចូវ ចុងគួរ និងប្រធាននាយកដ្ឋាននានាដែលពាក់ព័ន្ធ លោក កាង ម៉ៅចៅ ឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជា លោក លូ យី ប្រធានគណៈកម្មាធិការបដិវត្តន៍នៃឃុំប្រជាជនមិត្តភាពចិន-កម្ពុជា។

## ពិធីជប់លៀងដ៏ធំនៅរដ្ឋធានីប៉េកាំងដើម្បីផ្តល់កិត្តិយសដល់គណៈប្រតិភូនៃ FUNK និង GRUNK

**ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៧៤**

កាលពីរាត្រីថ្ងៃម្សិលមិញ លោក ជូ អេន ឡាយ នាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សាកិច្ចការរដ្ឋ បានរៀបចំពិធីជប់លៀងដ៏ធំមួយ ដើម្បីផ្តល់កិត្តិយសដល់គណៈប្រតិភូ FUNK និង GRUNK ដែលមានលោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ជាប្រធាន លោកទីប្រឹក្សាពិសេស អៀង សារី ជាអនុប្រធាន។

មានវត្តមានក្នុងពិធីជប់លៀងនោះមាន សម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋ និងជាប្រធាននៃ FUNK និងអ្នកម្នាងម៉ូនិច សីហនុ សម្តេច ប៉ែន នុត នាយករដ្ឋមន្ត្រីនៃ GRUNK និងជាប្រធានការិយាល័យនយោបាយនៃគណៈមជ្ឈិមរបស់ FUNK និងភរិយា។

ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងពិធីជប់លៀងនោះផងដែរ សមាជិកនៃ FUNK រដ្ឋមន្ត្រីនានានៃ GRUNK សមាជិកញាតិវង្ស និងជនកម្ពុជាផ្សេងទៀតដែលកំពុងស្ថិតនៅទីក្រុងប៉េកាំង។

ខាងភាគីចិន មានថ្នាក់ដឹកនាំបក្ស និងរដ្ឋាភិបាលចិន លោក យ៉េ គានយីង លោក លី ស៊ាននាន និងភរិយា លោក វូ តេ និង លោក ស៊ូ ចេនហ្សួរ ព្រមទាំងលោក កេង ពាវ ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិនៃគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន លោក គី ប៉េងហ្វី រដ្ឋមន្ត្រីក្រសួងការបរទេស លោក លី គាង រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្រៅប្រទេស លោក លាវ ស៊ានពីង រដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ លោក ស៊ាវ គឹងគួង អនុរដ្ឋមន្ត្រីក្រសួងការពារជាតិ និងលោក លី តា នាយអគ្គសេនាធិការរងនៃកងទ័ពប្រជាជនរំដោះចិន។

សមាជិកគណៈអចិន្ត្រៃយ៍សភាប្រជាជនចិន ព្រមទាំងអ្នកតំណាងនាយកដ្ឋាននៃគណៈមជ្ឈិមបក្សកុម្មុយនីស្តចិន អ្នកតំណាងរដ្ឋាភិបាល និងអ្នកតំណាងកងទ័ពប្រជាជនរំដោះប្រទេសចិន អ្នកតំណាងគណៈកម្មាធិការបដិវត្តន៍នៃរដ្ឋធានីប៉េកាំង និងសមាគមន៍ប្រជាជនចិនដើម្បីមិត្តភាពជាមួយបរទេស ក៏បានចូលរួមក្នុងឱកាសនោះផងដែរ។

មានវត្តមានក្នុងឱកាសនោះ បណ្តាអគ្គរដ្ឋទូតនៃប្រទេសនានាដែលកំពុងបំពេញបេសកកម្មការទូតនៅប្រទេសចិន។

លោកនាយករដ្ឋមន្ត្រី ជូ អេន ឡាយ និងឧបនាយករដ្ឋមន្ត្រី ខៀវ សំផន បានឡើងថ្លែងសន្ទរកថាក្នុងឱកាសពិធីជប់លៀងនោះ។

ក្រុមភ្លេងបានប្រគុំភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីលោកនាយករដ្ឋមន្ត្រី ជូ អេនឡាយ បានឡើងថ្លែងសន្ទរកថា ហើយបានប្រគុំភ្លេងជាតិនៃសាធារណរដ្ឋប្រជាមានិតចិន បន្ទាប់ពីលោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន បានឡើងថ្លែងសន្ទរកថាមក។

ពិធីជប់លៀងបានប្រព្រឹត្តទៅក្នុងបរិយាកាសកក់ក្តៅ ប្រកបដោយមិត្តភាពប្រយុទ្ធរវាងប្រជាជនកម្ពុជា និងប្រជាជនចិន។ ក្រុមភ្លេងក៏បានប្រគុំនូវចម្រៀងបដិវត្តន៍កម្ពុជា "ចម្រៀងនៃកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិ" និងបទ "ប្រជាជនកម្ពុជាគ្រប់ជាតិសាស្ត្រ រួបរួមគ្នាក្រោមទង់រណសិរ្សរួបរួមជាតិកម្ពុជា" ចម្រៀងដែលជាព្រះរាជនិពន្ធរបស់ សម្តេច នរោត្តម សីហនុ "ការនឹករលឹកដល់ប្រទេសចិន" ព្រមទាំងចម្រៀងបដិវត្តន៍ចិនដែលមានចំណងជើងថា "បុប្ផាមិត្តភាពរីកស្គុសស្គាយ" និង "ជំហានសាមគ្គីភាព និងមិត្តភាព"។

## សន្ទរកថារបស់លោកនាយករដ្ឋមន្ត្រី ជូ អេន ឡាយ ក្នុងពិធីជប់លៀង

**ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៧៤**

លោក ជូ អេនឡាយ នាយករដ្ឋមន្ត្រីនៃក្រុមប្រឹក្សាកិច្ចការរដ្ឋនៃសាធារណរដ្ឋប្រជាមានិតចិន បានឡើងថ្លែងសន្ទរកថានៅក្នុងពិធីជប់លៀង ដែលលោកបានរៀបចំកាលពីថ្ងៃទី ១ ខែ មេសា ដើម្បីផ្តល់ជាកិត្តិយសដល់គណៈប្រតិភូនៃ FUNK និង GRUNK ដែលមាន លោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ជាប្រធាន និងលោកទីប្រឹក្សាពិសេស អៀង សារី ជាអនុប្រធាន។

ខាងក្រោមនេះគឺជាអត្ថបទសន្ទរកថាទាំងស្រុង៖

សម្តេច នរោត្តម សីហនុ និងអ្នកម្នាង ជាទីគោរព !
សម្តេចនាយករដ្ឋមន្ត្រី ប៉ែន នុត និងលោកជំទាវ ជាទីគោរព !
ឯកឧត្តមប្រធានគណៈប្រតិភូ ខៀវ សំផន ជាទីគោរព !
ឯកឧត្តមអនុប្រធានគណៈប្រតិភូ អៀង សារី ជាទីគោរព !
ភ្ញៀវទាំងអស់នៃគណៈប្រតិភូ FUNK និង GRUNK !
មិត្ត និងសមមិត្តទាំងអស់ជាទីរាប់អាន !

ក្រោមការអញ្ជើញរបស់រដ្ឋាភិបាលចិន គណៈប្រតិភូនៃរណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានលោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន ជាប្រធាន និងលោកទីប្រឹក្សាពិសេស អៀង សារី ជាអនុប្រធាន បានអញ្ជើញមកបំពេញទស្សនកិច្ចជាផ្លូវការ និងជាលក្ខណៈមិត្តភាពនៅក្នុងប្រទេសរបស់យើង ដោយបានពាំនាំមកជាមួយនូវដំណឹងល្អអំពីជ័យជំនះដែលដណ្តើមបានដោយប្រជាជនកម្ពុជា នៅក្នុងសង្គ្រាមតស៊ូប្រឆាំងនឹងការឈ្លានពានរបស់អាមេរិកាំងដើម្បីស្រោចស្រង់ជាតិ ហើយបានពាំនាំផងដែរ នូវមនោសញ្ចេតនាមិត្តភាពដ៏ជ្រាលជ្រៅដែលមិត្តរួមអាវុធទាំងឡាយនៅសមរភូមិមុខកម្ពុជាសម្តែងចំពោះប្រជាជនចិន។ យើងខ្ញុំមានការសប្បាយរីករាយជាខ្លាំង។ ក្នុងនាមរដ្ឋាភិបាល និងប្រជាជនចិន ខ្ញុំសូមសម្តែងនូវការជូនពរ និងការស្វាគមន៍យ៉ាងកក់ក្តៅ ព្រមទាំងការកើតសរសើរដ៏ខ្ពង់ខ្ពស់ជូនចំពោះលោកប្រធានគណៈប្រតិភូ ខៀវ សំផន និងជូនចំពោះលោកអនុប្រធានគណៈប្រតិភូ អៀង សារី ព្រមទាំងភ្ញៀវកិត្តិយសទាំងអស់នៃគណៈប្រតិភូផងដែរ។

អ្វីដែលធ្វើឲ្យយើងខ្ញុំមានសេចក្តីសោមនស្សរីករាយទៀតនោះ គឺសម្តេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា និងព្រះមហេសី ព្រមទាំងលោកនាយករដ្ឋមន្ត្រី សម្តេច ប៉ែន នុត ព្រមទាំងលោកស្រី ប៉ែន នុត ក៏បានយាង និងអញ្ជើញចូលរួម ដើម្បីផ្តល់ជាកិត្តិយសដល់ពិធីជប់លៀង ក្នុងរាត្រីនេះផងដែរ។ យើងខ្ញុំសូមថ្លែងនូវអំណរអស់គុណដ៏ជ្រាលជ្រៅចំពោះកាយវិការទាំងនេះ។

អស់រយៈពេលបួនឆ្នាំ ដែលចក្រពត្តិអាមេរិកបានញុះញង់ដោយឥតអៀនខ្មាស់ឲ្យបន លន់ នល់ សិរីមតៈ ធ្វើរដ្ឋប្រហារប្រតិកិរិយា ហើយបានធ្វើការឈ្លានពានយ៉ាងគំហុកមកលើប្រទេសកម្ពុជា។ នៅក្នុងពេលវេលាដ៏សំខាន់ ដែលប្រទេសជាតិរបស់ខ្លួនធ្លាក់ទៅក្នុងគ្រោះអាសន្ន ប្រជាជនកម្ពុជាបានកាន់អាវុធដោយគ្មានរួញរា ហើយបានរួបរួមគ្នាក្រោមទង់រណសិរ្សរួបរួមជាតិកម្ពុជាដែលមានសម្តេចព្រះប្រមុខរដ្ឋ នរោត្តម សីហនុ ជាប្រធាន ហើយពួកគេបានធ្វើសង្គ្រាមតស៊ូប្រឆាំងនឹងការឈ្លានពានរបស់ចក្រពត្តិអាមេរិក ដើម្បីធ្វើការស្រោចស្រង់ជាតិ។ ក្នុងអំឡុងបួនឆ្នាំកន្លងទៅ ប្រជាជនកម្ពុជាដ៏អង់អាចក្លាហាន ដែលពុំព្រមចុះញ៉ម មិនខ្លាចនឹងធ្វើពលីកម្ម ចង់បាននូវឯករាជ្យម្ចាស់ការ បានព្យាយាមតស៊ូធ្វើសង្គ្រាមប្រជាជន ហើយដណ្តើមបាននូវជ័យជំនះដ៏ចិញ្ចាចចញ្ចែងរាប់មិនអស់។ ដោយប្រើប្រាស់នូវអាវុធ ពួកគេបានបង្កើតនូវស្ថានភាពមួយដ៏អស្ចារ្យ។ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា បានទទួលជោគជ័យយ៉ាងខ្លាំងក្លានៅក្នុងអណ្តាតភ្លើងសង្គ្រាមដ៏សន្ធោសន្ធៅ។ ដោយផ្សារភ្ជាប់ទៅនឹងកម្លាំងរបស់មហាជន កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាបានធ្វើការប្រយុទ្ធប្រកបដោយវីរភាព ដោយបានធ្វើឲ្យកម្លាំងរបស់សត្រូវចុះខ្សោយ និងបានរំដោះទឹកដីបាន

ជាង ៩០ ភាគរយ ព្រមទាំងរំដោះប្រជាជនបានជាង ៨០ ភាគរយ នៃប្រទេសទាំងមូលផងដែរ ទោះបីជាពួកគេជាអ្នកផ្តួចផ្តើមនៅក្នុងសង្គ្រាមនេះក៏ដោយ។ ចាប់តាំងពីដើមរដូវប្រាំងនេះមក កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាបានធ្វើការវាយសម្រុកលើសមរភូមិនានា បានធ្វើការវាយប្រហារទៅលើសត្រូវដែលមានមូលដ្ឋាននៅភ្នំពេញ និងនៅក្នុងតំបន់ដទៃទៀត ហើយទទួលបានជោគជ័យដ៏ត្រចះត្រចង់។ ប្រជាជនចិនមានការសប្បាយរីករាយ និងត្រូវបានជំរុញទឹកចិត្តតាមរយៈជ័យជំនះដែលប្រជាជនកម្ពុជាជាបងប្អូនដណ្តើមបាន។ យើងខ្ញុំសូមឆ្លៀតយកនូវឱកាសនេះ ដើម្បីសម្តែងនូវសេចក្តីអបអរសាទរដ៏កក់ក្តៅជូនចំពោះមិត្ត សមមិត្ត និងភ្ញៀវកិត្តិយសទាំងអស់ដែលមានវត្តមាននៅទីនេះ។

ប្រទេសកម្ពុជា ដែលមានប្រជាជនតែជាង ៧ លាន នាក់ មានសេចក្តីក្លាហានក្នុងការប្រឈមមុខតទល់នឹងចក្រពត្តិនិយមអាមេរិក ដែលត្រូវបានចាត់ទុកថាជា “មហាអំណាច” ហើយទទួលបាននូវជ័យជំនះជាបន្តបន្ទាប់។ នេះជាព្រឹត្តិការណ៍មួយដ៏អស្ចារ្យ។ ភស្តុតាងជាក់ស្តែងមួយទៀត គឺថា “ប្រជាជននៃប្រទេសតូចមួយនឹងធ្វើការវាយប្រយុទ្ធតទល់នឹងការឈ្លានពានរបស់ប្រទេសដ៏ធំមួយ ប្រសិនណាពួកគេហ៊ានក្រោកឡើងដើម្បីធ្វើការប្រយុទ្ធ ចាប់កាន់អាវុធ និងក្តាប់នូវជោគវាសនានៃប្រទេសជាតិរបស់ពួកគេ”។ ការតស៊ូប្រយុទ្ធរបស់មិត្ត និងសមមិត្តទាំងអស់ បានជំរុញនិងលើកទឹកចិត្តដល់ប្រជាជាតិ និងប្រជាជននៅលើពិភពលោក ហើយការវាយប្រយុទ្ធនេះគឺជាឧទាហរណ៍មួយដ៏ចិញ្ចាចចិញ្ចែង សម្រាប់ការតស៊ូប្រយុទ្ធបដិវត្តន៍របស់ប្រជាជននៅគ្រប់ទីកន្លែង ដើម្បីប្រឆាំងនឹងចក្រពត្តិនិយម និងបានរួមវិភាគទានដ៏មានតម្លៃដល់ការតស៊ូប្រយុទ្ធនេះ។

បុព្វហេតុដ៏ត្រឹមត្រូវទទួលបាននូវការគាំទ្រដ៏សន្ធឹកសន្ធាប់ ចំណែកឯបុព្វហេតុខុសឆ្គង ទទួលបាននូវការគាំទ្រស្ដួចស្ដើង។ តាំងពីដំបូងទី ការតស៊ូប្រយុទ្ធដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជា ត្រូវបានប្រជាជននៅលើពិភពលោកសម្តែងនូវសណ្តានចិត្ត និងគាំទ្រជាខ្លាំង។ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាក្នុងនាមជារដ្ឋាភិបាលស្របច្បាប់តែមួយគត់នៃប្រជាជនកម្ពុជា ត្រូវបានទទួលស្គាល់ចាប់តាំងពីពេលបង្កើតឡើងដំបូង ពីសំណាក់បណ្តារដ្ឋជាច្រើននៅលើពិភពលោក។ រាជរដ្ឋាភិបាលរួបរួមជាតិបានសម្រេចចូលរួមជាមួយក្រុមបណ្តាប្រទេសតតិយលោក ដែលពួកគេបានពង្រឹងចំណងសាមគ្គីភាព និងជួយគ្នាទៅវិញទៅមក។ លើសពីនេះ រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាបានដើរតួនាទីយ៉ាងសកម្ម និងទទួលបាននូវកិត្យានុភាពដ៏ខ្ពង់ខ្ពស់នៅលើឆាកអន្តរជាតិ។

មិត្ត និងសមមិត្តទាំងអស់ជាទីមេត្រី !

នាពេលបច្ចុប្បន្ននេះ ស្ថានភាពលើឆាកអន្តរជាតិមានលក្ខណៈអំណោយផលខ្លាំងដល់ការតស៊ូប្រយុទ្ធបដិវត្តន៍របស់បណ្តាប្រជាជននៅលើពិភពលោកប្រឆាំងទៅនឹងចក្រពត្តិនិយម។ ភាពក្រឡាប់ចាក់នានាដែលកើតមានឡើងនៅក្នុងពិភពលោក បានធ្វើឲ្យពួកចក្រពត្តិនិយមធ្លាក់ទៅក្នុងភាពវឹកវរ។ ទន្ទឹមគ្នានោះ ភាពក្រឡាប់ចាក់នោះបានដាស់សតិប្រជាជន ហើយបានជំរុញឲ្យពួកគេធ្វើសង្គ្រាម និងបានរួមចំណែកជាបន្តបន្ទាប់ដល់ការតស៊ូប្រយុទ្ធបដិវត្តន៍របស់ប្រជាជននៅគ្រប់ទីកន្លែងប្រឆាំងទៅនឹងពួកចក្រពត្តិនិយម។ ការតស៊ូប្រយុទ្ធរបស់បណ្តាប្រទេសតតិយលោក នៅអាស៊ី អាហ្វ្រិក និងនៅអាមេរិកឡាទីន ប្រឆាំងនឹងពួកចក្រពត្តិនិយម អនុត្តរភាពនិយម អាណានិគមនិយម អាណានិគមនិយមសម័យថ្មី ប្រកាន់ពូជសាសន៍និយម និងចលនានៃការបង្កើតរដ្ឋហ្ស៊ីហ្វូនិយម មានការរីកលូតលាស់យ៉ាងស៊ីជម្រៅ និងយ៉ាងពេញទំហឹង។ ប្រទេសដែលចង់បានឯករាជ្យ ប្រជាជាតិដែលចង់បានការរំដោះជាតិ និងប្រជាជនដែលចង់ធ្វើបដិវត្តន៍ បានក្លាយទៅជាចរន្តដែលមិនអាចទប់ទល់បានក្នុងប្រវត្តិសាស្ត្រ។ ប្រឈមមុខទៅនឹងរលកនៃចលនាបដិវត្តន៍ប្រឆាំងនឹងចក្រពត្តិនិយម របស់បណ្តាប្រជាជនក្នុងពិភពលោក មហាអំណាចទាំងពីរបានធ្វើការប្រកាសគ្រប់ទីកន្លែង ស្នើសុំឲ្យមាន "ការសម្រួលស្ថានការណ៍" ក្នុងគោលបំណងដើម្បីលាក់បាំងនូវការប្រកួតប្រជែងរបស់ខ្លួន និងបំបែកបំបាក់ការវាយប្រយុទ្ធរបស់ប្រជាជន។ ដោយឡែក មានអង្គហេតុរាប់មិនអស់ដែលបានលាតត្រដាងនូវការភូតកុហករបស់ពួកគេតាំងពីយូរណាស់មកហើយ៖ ប្រជាជនបដិវត្តន៍មិនបានផ្តល់តម្លៃទៅលើអ្វីដែលហៅថា "សន្តិភាពដែលស្ថិតស្ថេរ" ឬ "សន្តិភាពសម្រាប់មនុស្សជាតិមួយជំនាន់" នោះឡើយ។ ដរាបណានៅតែមានពួកចក្រពត្តិនិយម បដិវត្តន៍ និងសង្គ្រាមមិនអាចជៀសផុតបានឡើយ។ ពិភពលោកទាំងមូលនឹងទទួលរងនូវភាពក្រឡាប់ចាក់ជារៀងរហូត។

នៅឥណ្ឌូចិន ដំណើរវិវត្តនៃស្ថានការណ៍មានលក្ខណៈអំណោយផលខ្លាំង។ នៅខណៈដែលសភាពការណ៍មានការរីកចម្រើនខ្លាំងនៅប្រទេសកម្ពុជានៅក្នុងការតស៊ូប្រឆាំងនឹងការឈ្លានពានរបស់អាមេរិកាំង ដើម្បីស្រោចស្រង់ជាតិ ប្រជាជនវៀតណាម និងប្រជាជនឡាវដណ្តើមបានជ័យជំនះឥតឈប់ឈរនៅក្នុងការតស៊ូប្រយុទ្ធដ៏ត្រឹមត្រូវរបស់ខ្លួន។ ការចុះហត្ថលេខា លើកិច្ចព្រមព្រៀងក្រុងប៉ារីសស្តីអំពីករណីប្រទេសវៀតណាម និងកិច្ចព្រមព្រៀងទីក្រុងវៀងចន្ទន៍ស្តីអំពីប្រទេសឡាវ បានកំណត់នូវការចាប់ផ្តើមនូវដំណាក់កាលថ្មីនៃការតស៊ូប្រយុទ្ធរបស់ប្រជាជនវៀតណាម និងឡាវ។ ដោយជ្រោង

ទង់នៃសន្និសីទឱ្យខ្ពស់ត្រដែតក្នុងជំនួបកំពូលនៃបណ្ដាប្រជាជនឥណ្ឌូចិន ទង់របស់អង្គភាព និង សមរភូមិប្រយុទ្ធ ប្រជាជនទាំងបីនៃឥណ្ឌូចិនបានធ្វើការគាំទ្រគ្នា និងលើកទឹកចិត្តគ្នាទៅវិញទៅមក ដែលជំរុញឱ្យបុព្វហេតុបដិវត្តន៍មានការរីកចម្រើនទៅមុខ។ វាជាក់ច្បាស់ណាស់ ពួកគេត្រូវប្រឈមមុខទៅនឹងភារកិច្ចប្រយុទ្ធដ៏ធំធេង។ ដោយមានជំនួយគាំទ្រ និងការញុះញង់ពីសំណាក់សហរដ្ឋអាមេរិក បនអាយ៉ងក្រុងសៃហ្គនបានរំលោភជាបន្តបន្ទាប់នូវខដែលពាក់ព័ន្ធនឹងបទឈប់បាញ់ ដោយអនុវត្តនូវនយោបាយ "សន្តិវិធី" បានបើកយុទ្ធនាការយោធា "ទន្ទ្រាន" និងជិះជាន់សង្កត់សង្កិនលើសេរីភាព និងសិទ្ធិប្រជាធិបតេយ្យរបស់ប្រជាជនវៀតណាមខាងត្បូង ដោយបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មធ្ងន់ធ្ងរ រំលោភលើកិច្ចព្រមព្រៀងក្រុងប៉ារីស។ កងកម្លាំងស្តាំនិយមជ្រុលនៅវៀងចន្ទន៍ តែងតែប៉ុនប៉ងធ្វើការរំខានដល់ការអនុវត្តកិច្ចព្រមព្រៀងទីក្រុងវៀងចន្ទន៍។ ពាក់ព័ន្ធនឹងប្រទេសកម្ពុជា សហរដ្ឋអាមេរិកបានបន្តផ្តល់ដល់បនក្បត់ លន់ នល់ នូវជំនួយផ្នែកយោធា និងសេដ្ឋកិច្ចដ៏សន្ធឹកសន្ធាប់ ហើយបានបញ្ជូនទីប្រឹក្សា និងអ្នកជំនាញការ ក្នុងគោលដៅដើម្បីជួយសង្គ្រោះរបបអាយ៉ងមួយនេះ។ ដោយឡែក មិនមានអ្វីអាចរារាំងដល់ដំណើរឆ្ពោះទៅមុខរបស់ប្រជាជនឥណ្ឌូចិនបានឡើយ។ យើងមានជំនឿយ៉ាងមុតមាំថា ជ័យជំនះគឺជាជ័យជំនះរបស់វីរប្រជាជនទាំងបីនៃឥណ្ឌូចិន។

ប្រជាជនចិន និងប្រជាជនកម្ពុជាគឺជាមិត្តរួមអាវុធ និងជាបងប្អូនដ៏ជិតស្និទ្ធនិងគ្នា។ ប្រជាជនទាំងពីរតែងតែបញ្ចេញនូវសណ្ដានចិត្ត និងធ្វើការគាំទ្រគ្នាទៅវិញទៅមក ដោយបានផ្សារភ្ជាប់រវាងគ្នានូវចំណងមិត្តភាពដ៏ជ្រាលជ្រៅរវាងគ្នា និងគ្នា។ ប្រទេសចិនគឺជាប្រទេសសង្គមនិយមមួយ ពួកយើងគឺជាអ្នកអន្តរជាតិវណ្ណៈអធន។ លោកប្រធាន ម៉ៅ បានបង្រៀនយើងខ្ញុំថា៖ "ប្រជាជនដែលបានធ្វើបដិវត្តន៍ដោយជោគជ័យ ត្រូវជួយដល់ប្រជាជនដែលកំពុងប្រយុទ្ធដើម្បីធ្វើការរំដោះជាតិ"។ ស្របគ្នាទៅនឹងការបង្រៀននេះ យើងខ្ញុំសូមធ្វើការគាំទ្រដាច់ខាតចំពោះការវាយប្រយុទ្ធដ៏ត្រឹមត្រូវរបស់ប្រជាជនកម្ពុជា យើងសូមធ្វើការគាំទ្រ "សេចក្តីថ្លែងការណ៍ ៥ ចំណុច" របស់សម្តេចព្រះប្រមុខរដ្ឋនរោត្តម សីហនុ និងកម្មវិធីនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលបញ្ជាក់នៅក្នុងសមាជជាតិកម្ពុជាក្នុងឆ្នាំ ១៩៧៣។ ប្រជាជនចិនបានស្ថិតនៅយ៉ាងប្រកិតជាមួយប្រជាជនកម្ពុជា ដូចនៅក្នុងអតីតកាលដែរ ប្រជាជនចិនបានគាំទ្រអស់ពីកម្លាំងកាយចិត្តដល់ប្រជាជនកម្ពុជាក្នុងការវាយប្រយុទ្ធប្រឆាំងនឹងអាមេរិកាំងឈ្លានពាន ដើម្បីស្រោចស្រង់ជាតិ រហូតដល់ទទួលបានជោគជ័យទាំងស្រុង។

ឥឡូវនេះ ខ្ញុំសូមស្នើមិត្ត សមមិត្ត អស់លោក លោកស្រី មេត្តាលើកកែវឡើងដើម្បីជូនពរដល់៖

មហាជ័យជំនះរបស់ប្រជាជនកម្ពុជាដែលទទួលបានក្នុងសង្គ្រាមតស៊ូប្រឆាំងនឹងការឈ្លានពានរបស់អាមេរិក ដើម្បីស្រោចស្រង់ជាតិ

ដើម្បីមិត្តភាពដ៏ធំធេង និងសាមគ្គីភាពដ៏រឹងមាំរវាងប្រជាជនចិន និងប្រជាជនកម្ពុជា។

ដើម្បីមិត្តភាពដ៏ធំធេង និងសាមគ្គីភាពដ៏រឹងមាំរវាងប្រជាជនចិន និងបណ្ដាប្រជាជននៅឥណ្ឌូចិនទាំងអស់

ដើម្បីព្រះរាជសុខភាព និងព្រះជន្មាយុយឺនយូររបស់មហាក្សត្រិយានី ស៊ីសុវត្ថិ កុសមៈ

ដើម្បីព្រះរាជសុខភាពរបស់ សម្ដេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃប្រទេសកម្ពុជា និងព្រះមហេសី

ដើម្បីសុខភាពរបស់លោកនាយករដ្ឋមន្ត្រី សម្ដេច ប៉ែន នុត និងលោកជំទាវ

ដើម្បីសុខភាពរបស់លោកប្រធានគណៈប្រតិភូ ខៀវ សំផន និងលោកអនុប្រធាន អៀង សារី

ដើម្បីសុខភាពរបស់ភ្ញៀវកិត្តិយសទាំងអស់ដែលជាសមាជិកនៃគណៈប្រតិភូ

ដើម្បីសុខភាពរបស់មិត្តកម្ពុជាដទៃទៀតដែលមានវត្តមាននៅទីនេះ

ដើម្បីសុខភាពរបស់ប្រមុខបេសកកម្មការទូតទាំងឡាយ ព្រមទាំងលោកស្រី ដែលមានវត្តមាននៅទីនេះ និង

ដើម្បីសុខភាពរបស់សមមិត្ត និងមិត្តទាំងឡាយរបស់យើង ដែលមានវត្តមាននៅក្នុងពិធីជប់លៀងនេះ។

## ប្រធានាធិបតី ម៉ៅ សេទុង ទទួលជួបសន្ទនាការជាមួយគណៈប្រតិភូនៃ FUNK និង GRUNK

### ទីភ្នាក់ងារសារព័ត៌មានកម្ពុជា ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៩៧៤

លោកប្រធានាធិបតី ម៉ៅ សេទុង បានទទួលជួបធ្វើសន្ទនាការ កាលពីថ្ងៃម្សិលមិញ ជាមួយគណៈប្រតិភូនៃ FUNK និង GRUNK ដែលបច្ចុប្បន្នកំពុងបំពេញទស្សនកិច្ចជាលក្ខណៈមិត្តភាព

ផ្លូវការ នៅសាធារណរដ្ឋប្រជាមានិតចិន។ គណៈប្រតិភូដឹកនាំដោយលោក ខៀវ សំផន សមាជិកការិយាល័យនយោបាយនៃគណៈមជ្ឈិមនៃ FUNK ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនៃ GRUNK និងជាអគ្គមេបញ្ជាការកងម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា និងលោក អៀង សារី ទីប្រឹក្សាពិសេសអនុប្រធានក្រុមប្រឹក្សានៃ GRUNK និងជាអនុប្រធាននៃគណៈប្រតិភូ។

សម្តេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ និងជាប្រធាននៃ FUNK និងសម្តេច ប៉ែន នុត ប្រធានការិយាល័យនយោបាយនៃគណៈមជ្ឈិមនៃ FUNK និងនាយករដ្ឋមន្ត្រីនៃ GRUNK បានមានវត្តមាននៅក្នុងជំនួបនោះផងដែរ។

មានវត្តមាននាឱកាសនោះផងដែរ លោក ជូ អេនឡាយ នាយករដ្ឋមន្ត្រីនៃប្រទេសចិន លោង ហ្វ័ង ហុង វេន អនុប្រធានាធិបតី និងលោក ហ្វ័ង ហៃចុង រដ្ឋលេខាធិការ និងអ្នកឯទៀត។

លោកប្រធានាធិបតី ម៉ៅ សេទុង បានចាប់ដៃភ្ញៀវកិត្តិយសកម្ពុជារលាក់យ៉ាងយូរ ព្រមទាំងសម្តែងនូវការជូនពរស្វាគមន៍យ៉ាងកក់ក្តៅផងដែរ។ លោកឧបនាយករដ្ឋមន្ត្រី ខៀវ សំផន បានមានប្រសាសន៍ថា៖ “រាល់យុទ្ធជន និងកម្មាភិបាលកម្ពុជានៅក្នុងប្រទេសទាំងអស់បានផ្តាំផ្ញើតាមរយៈខ្ញុំឲ្យធ្វើការជូនពរដល់លោកប្រធាន ម៉ៅ ដល់បក្សកុម្មុយនីស្តចិន និងប្រជាជនចិន ដែលបានជួយគាំទ្រដល់ប្រជាជនកម្ពុជាក្នុងការប្រយុទ្ធដើម្បីឯករាជ្យជាតិ”។

ជំនួប ដែលបានចាប់ផ្តើមពីម៉ោង ៩ ព្រឹក បានបញ្ចប់ទៅនៅម៉ោង ១០ និង ៤០ នាទី។ ជំនួបនេះបានប្រព្រឹត្តទៅនៅក្នុងបរិយាកាសកក់ក្តៅ ប្រកបដោយភាពស្និទ្ធស្នាល មិត្តភាព និងសាមគ្គីភាពរឹងមាំ។